

# “ខ្យល់ព្យុះកាន់តែញឹក ហើយទឹកកាន់តែខ្សត់”

## អាកាសធាតុប្រែប្រួលជីវិតផ្លាស់ប្ដូរ

## គម្រោងរូបថតឯកសារសហគមន៍មូលដ្ឋាន

# “More Storms and No Water”

**Changing Climate, Changing Life - Koh Rong Archipelago, Cambodia.**
**A Community-Based Photo-Documentary Project**

បោះពុម្ពផ្សាយដោយមូលនិធិកោះសង្សា ដែលមានការសហការជាមួយសហគមន៍ភូមិព្រែកស្វាយនៅប្រជុំកោះរ៉ុង។
ដោយមានការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី និងអង្គការភ្លែនអន្តរជាតិ ( កម្ពុជា )។

© 2017

ISBN-13:978-9924-9167-0-3

រក្សាសិទ្ធគ្រប់យ៉ាង។ គ្រប់ផ្នែកទាំងអស់នៃសៀវភៅមួយនេះមិនត្រូវបានអនុញ្ញាតឲ្យថតចម្លង ដោយគ្មានការអនុញ្ញាត
ជាលាយលក្ខណ៍អក្សរជាមុនពីអ្នកនិពន្ធឡើយ។ សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង: wayne@songsaa.com

មូលនិធិកោះសង្សាគឺជាអង្គការមិនស្វែងរកប្រាក់ចំណេញក្នុងស្រុកមួយដែលធ្វើការទៅលើការលើកកម្ពស់សុខភាព និងសុខុមាលភាពនៃបរិស្ថានតំបន់
ឆ្នេរសមុទ្រនៃប្រទេសកម្ពុជា។ សម្រាប់ ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ : www.songsaa.com

គម្រោងនេះត្រូវបានអនុវត្តក្រោមកិច្ចសហការគ្នាជាមួយសមាជិកសហគមន៍ភូមិព្រែកស្វាយ, សង្កាត់កោះរ៉ុង នៃប្រជុំកោះរ៉ុង។
ការប្តេជ្ញាចិត្ត និងភាពសប្បាយរីករាយក្នុងការប្រាប់ពីរឿងរ៉ាវរបស់ពួកគេជាចំនុចមួយដែលជួយឲ្យ គម្រោងមានភាពជោគជ័យ។
យើងសូមអរគុណសហគមន៍ព្រែកស្វាយ ហើយសង្ឃឹមថាសៀវភៅនេះនឹងនាំមកនូវការយកចិត្តទុកដាក់ទៅការបម្រែបម្រួល "អាកាសធាតុ" និងជួយនាំ
មកនូវការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងពេលអនាគត។ ។

Published by Song Saa Foundation in collaboration with the community of Prek Svay village, Koh Rong archipelago.
With support from the Asian Development Bank and Plan International Cambodia.

© 2017

ISBN-13:978-9924-9167-0-3
All rights reserved. No part of this publication may be copied without prior written permission from the author.
For information please contact: wayne@songsaa.com
The Song Saa Foundation is a local-based not-for-profit organisation promoting the health and well being of the coastal and marine environments of Cambodia. Learn more at www.songsaa.com

This project was undertaken in collaboration with community members of Prek Svay village, Koh Rong Island, Koh Rong Archipelago. Their commitment to the project and their enthusiasm for telling their stories lay at the centre of its success. We thank them and hope that the light shed on their 'climate change' lives will result in a positive difference.

Front cover image: Justin Mott. Rear cover image: Jeremy Holden.

"  សេណារីយ៉ូដែលត្រូវតែផ្តោតអារម្មណ៍នៅពេលនេះគឺរង់ចាំមើលថា  តើនឹងមានមហន្តរាយអាកាសធាតុអ្វីខ្លះនឹងកើតឡើង " ប្រសិនបើយើងអនុញ្ញាតឱ្យពិភពលោកមានការកើនឡើងសីតុណ្ហភាពកើនលើសពី២អង្សាសេបើប្រៀបធៀបទៅនឹងអាកាសធាតុមុនឆ្នាំ ១៨៥០។ ប៉ុន្តែប្រទេសមួយចំនួននៅលើពិភពលោក  បានកើតមានមហន្តរាយរួចទៅហើយ។ ប្រសិនបើយើងបានស្តាប់អ្នកដែលកំពុងរស់នៅទីកន្លែងដែលកំពុងតែទទួលរងនូវការបំផ្លាញដោយទឹកជំនន់ការកាប់ព្រៃឈើ  និងការរំលោភទន្ទ្រានយកតំបន់ទីវាល  នូវអ្វីដែលនឹងត្រូវមកដល់នោះគឺ ការបំផ្លាញពិភពលោក។

*"The focus is on scenarios for 'what will happen', the climate catastrophe that awaits if we allow global temperatures to rise by more than two degrees celsius above pre-industrial levels. But in the edge-places of the world the catastrophe is happening already. If we listened to those whose lives are being destroyed by floods, deforestation and encroaching deserts, we would better understand what is coming: the total disruption of the world."*

Paul Mason, *PostCapitalism. A guide to our future*, 2015.

# វាមានសភាពក្ដៅ នៅក្រោមដំបូល

យើងចាប់ផ្ដើមធ្វើការនេះតាំងពីពាក់កណ្ដាលព្រឹកដោយជជែកគ្នាអំពីអត្ថន័យនៃការប្រែប្រួលអាកាសធាតុសម្រាប់ជីវិតរស់នៅរបស់ប្រជាជនដែលរស់នៅជុំវិញយើង ដែលជាអ្នករស់នៅលើកោះនៃប្រជុំកោះរ៉ុងនេះ។ មានមនុស្សដប់នាក់ដែលបានជួបជុំគ្នានៅលើយ៉រនៃសាលាសង្ក្សាលោកហ៊ីលីប៉ូនិងលោកហេតជាអ្នកសម្របសម្រួលសិក្ខាសាលានោះឈរនៅខាងមុខដែលលាយចម្រុះដោយបុរសនិងស្ត្រី ទាំងក្មេងទាំងចាស់អង្គុយជាពាក់កណ្ដាលរង្វង់នៅជុំវិញពួកគេ។

ជាញឹកញាប់នៅក្នុងវេទិកាប្រជុំ ស្ដីពីការប្រែប្រួលអាកាសធាតុគឺមានការពិភាក្សាទាំងនៅក្នុងជួររដ្ឋាភិបាល និងនៅតាមប្រពន្ធ័ផ្សព្វផ្សាយនានាអំពីបញ្ហាថ្មីៗ ដែលបានកើតឡើងដោយការប្រែប្រួលអាកាសធាតុ ហើយព័ត៌មាន និងរបាយការណ៍បន្ទាន់ទាំងនោះមិនបានផ្សព្វផ្សាយដល់ថ្នាក់ក្រោមឲ្យបានដឹងឡើយ។ ប៉ុន្តែការជួបប្រជុំរបស់សហគមន៍នេះស្ដីពីសារៈសំខាន់នៃបញ្ហា មិនបានបំភ្លេចនោះទេព្រោះសព្វថ្ងៃនេះការប្រែប្រួលអាកាសធាតុបាននឹងកំពុងកើតឡើង ហើយក៏នឹងកំពុងប៉ះពាល់ដល់អារម្មណ៍របស់មនុស្សគ្រប់គ្នានៅក្នុងអង្គប្រជុំនេះផងដែរ។

ដានីដែលជាប្រជាជនម្នាក់ដែលរស់នៅទីនេះយូរណាស់មកហើយ ហើយគាត់ក៏ជាមនុស្សដំបូងគេ ដែលបានចាប់ផ្ដើមពិភាក្សាអំពីបញ្ហាការប្រែប្រួលអាកាសធាតុនេះគាត់បាននិយាយយ៉ាងមឹងម៉ាត់ថា "សព្វថ្ងៃនេះពួកយើងតែងតែទទួលរងនូវខ្យល់ព្យុះហើយខ្សត់ទឹកប្រើប្រាស់"" ពីមុនមកយើងមិនដែលជួបសភាពបែបនេះនោះទេ"។ ប្រសិនបើសភាពបែបនេះនៅតែបន្តទៅទៀត ខ្ញុំមិនដឹងថាតើយើងនឹងរស់បានដោយរបៀបណាទេ មនុស្សជុំវិញដានីបានងក់ក្បាលយល់ស្របនឹងពាក្យសំដីនេះ"។

ជាការពិតណាស់ស្ត្រីនេះ និងអ្នកភូមិផ្សេងៗទៀតនៃប្រជុំកោះរ៉ុងបាននិយាយថា ការប្រែប្រួលអាកាសធាតុបានកើតឡើងច្រើនជាងការនិយាយ។ ហើយប្រទេសកម្ពុជា ជាប្រទេសមួយដែលត្រូវបានគេកត់ត្រាថាងាយទទួលរងគ្រោះបំផុត ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ វាធ្វើការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរទៅលើសុខភាព និងភាពរីកចំរើនរបស់មនុស្ស និងបរិស្ថាន។ ហើយវាពិតជាគួរឲ្យអស់សំណើចណាស់ដែលការប្រែប្រួលអាកាសធាតុបានកើតមានឡើងចំពោះដានី និងអ្នកជិតខាងរបស់គាត់ដោយមិនដឹងខ្លួន។

គម្រោងរូបថតឯកសារកោះរ៉ុងធ្វើឡើងដើម្បីបង្ហាញពីស្ថានភាពនិងផ្ដល់ជាសំលេងទៅកាន់អ្នកដែលមិនធ្លាប់បានឃើញ បានលឺពីការប្រែប្រួលអាកាសធាតុឲ្យពួកគេបានដឹងបានលឺ។

# It is hot under THE ROOF

We have been working since mid-morning, talking through the meaning of climate change for the lives of the people living around us—the islanders of the Koh Rong archipelago. There are ten people gathered on the balcony of the sustainability centre—Sala Song Saa—with Filippo and Het, the workshop facilitators, standing at the front, a mix of men and women, young and old, all of us in a semi-circle around them.

Often in the forums where climate change is discussed—official meetings and in the media—the immediacy of the issue can be lost beneath layers of statistics and reports. But in this community meeting the importance of the issue is not lost, because climate change is happening now and felt by everyone in this room.

It is Srey Dany, a long-time inhabitant, who cuts to the heart of the matter: "We often have more storms and no water" she states firmly, "it was not like this before." Around Srey Dany there are nods of approval, "if this goes on I am not sure how we will survive."

For this woman and the other villagers of the Koh Rong archipelago climate change is more than a theory, it is reality. For Cambodia, a country regularly listed as 'severely vulnerable' to the impacts of climate change, it poses a massive threat to human and environmental health and prosperity. Yet ironically it is the lives of those most exposed to it—people like Srey Dany and her neighbours—that often go unnoticed.

The Koh Rong photo-documentary project seeks to re-address this situation, offering a visual and narrative voice to those who go unseen and unheard in the discussion on climate change.

Wayne McCallum
Executive Director
Song Saa Foundation

# ប្រជុំ
# កោះរ៉ុង

ប្រជុំកោះរ៉ុងគឺជាក្រុមកោះច្រើនបញ្ចូលគ្នាដែលលាតសន្ធឹងនៅដែនទឹកភាគខាងត្បូងនៃប្រទេសកម្ពុជា។ តំបន់នេះគ្របដណ្តប់ដោយព្រៃរងទឹកភ្លៀង និងដើមឈើដែលដុះក្បែរច្រាំងដូចជាដើមដូងនិងឆ្នេរខ្សាច់។ ប្រជុំកោះនេះមិនមានមនុស្សរស់នៅនោះទេ លើកលែងតែកោះរ៉ុងនិងកោះរ៉ុងសន្ទឹម ដែលមានមនុស្សរស់នៅហើយវាក៏ជាកោះដែល ធំជាងគេក្នុងចំណោមប្រជុំកោះនោះផងដែរ។

ទោះបីជាកោះនៅប្រជុំកោះរ៉ុងមានទំហំតូចៗក៏ដោយ ក៏វាជាជម្រកដើម្បីឲ្យមានភាពសម្បូរបែប និងសហគមន៍ជីវចម្រុះសម្រាប់ជីវិតសត្វ និងរុក្ខជាតិ។ សត្វទាំងនោះរួមមានសត្វស្វា ប្រចៀវ ពង្រូល និងសត្វស្លាបជាច្រើនប្រភេទដូចជាសត្វកេងកង សត្វក្អែក, ឥន្ទ្រីសមុទ្រ ជ្រុងង៉ុ និង បក្សីជាច្រើនទៀតដែលរស់នៅក្នុងជីវចម្រុះនៃព្រៃរងទឹកភ្លៀង និងប្រភេទរុក្ខជាតិតំបន់ឆ្នេរ។ ដែនទឹកនៅប្រជុំកោះសម្បូរទៅដោយប្រភេទសត្វសមុទ្រចម្រុះជាច្រើនរស់នៅ។ ប្រភេទត្រីធំជាងគេបំផុតរបស់ពិភពលោក គឺត្រីបាឡែនបានបង្ហាញខ្លួនម្តងម្កាលនៅទីនោះ ខណៈពេលដែលអណ្តើកសមុទ្រចំនួនពីរប្រភេទ ជ្រូកទឹក និងប្រភេទនៃសេះសមុទ្រមួយចំនួនទៀតដែលកំពុងរងគ្រោះថ្នាក់នៅក្នុងប្រទេសកម្ពុជា បានបង្ហាញខ្លួននៅទីនោះ ហើយហៅទីនោះថាជាផ្ទះរបស់គេ។ វត្តមាននៃស្មៅសមុទ្រនៅជុំវិញកោះរ៉ុង និងការសំបូរផ្កាថ្មត្រូពិចដែលធ្វើឲ្យមានការកើនឡើងខ្លាំងនៃស្ថានប្រព័ន្ធដ៏កម្រក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលដើរតួនាទីសារះខាន់សម្រាប់បរិស្ថាន ។

កោះនេះគឺមានប្រជាជនរស់នៅប្រមាណ 3000នាក់ ហើយពួកគេអាចរស់នៅដោយសន្តិភាពដោយសារភាពអត់ធន់ និងការសម្របខ្លួនរបស់ពួកគេរស់នៅលើដី និងសមុទ្រ។

ការបង្កើតសួនបន្លែខ្នាតតូចនៅតាមផ្ទះ ការប្រមូលផលពីធនធានសមុទ្រ និងការងារក្រៅម៉ោងនៅតែមាន ហើយជាការងារ សំខាន់សម្រាប់ចិញ្ចឹមជីវិតរបស់ពួកគេ។ ការតាំងទីលំនៅជាច្រើន បានធ្វើឲ្យភូមិព្រែកស្វាយក្លាយជាភូមិដែលធំជាងគេនៅក្នុងប្រជុំកោះនេះហើយក៏ជាភូមិតែមួយគត់ដែលមានអនុវិទ្យាល័យសម្រាប់សិស្សានុសិស្សផងដែរ វាមិនបានរាប់បញ្ចូលពីទំហំ និងការងារជាមូលដ្ឋានរបស់មូលនិធិសង្ឃដែលមានសាលាសង្ឃជាមជ្ឈមណ្ឌលសម្រាប់អប់រំដល់ក្មេងៗនៅក្នុងភូមិនោះទេ។

# The Koh Rong **Archipelago**

The Koh Rong archipelago comprises a group of islands scattered across the southern waters of Cambodia. Clad in rainforest and fringed by coconut palms and sandy beaches, the archipelago's islands are largely uninhabited, save for Koh Rong Samloem and Koh Rong, the two largest in the group.




Although small in size the archipelago is home to a rich and vibrant community of plant and animal life. Macaques, bats, pangolins, and numerous bird species—hornbills, bee-eaters, drongo, sea eagles and terns—are common, along with a myriad of rainforest and coastal plant species.

The archipelago's waters also teem with a diversity of marine life. The world's largest fish, the whale shark, is an occasional visitor, while two species of sea turtle, dugong, and several types of seahorses call its waters home. The presence of seagrass beds, around Koh Rong, and numerous tropical reefs—increasingly rare ecosystems in Southeast Asia—are ecologically significant.

The islands are also home to 3000 native inhabitants. Resilient and adaptable, these people have sought to harmonise their lives with the land and sea. Small-scale home gardening, the harvesting of marine resources and part-time work remain the predominant livelihood activities. Prek Svay, the largest settlement in the archipelago, is the centre of a large and vibrant community, which includes the island's only secondary school. Fittingly, given its size and influence to the archipelago, it is also the base for the Song Saa Foundation and its dedicated sustainability centre, Sala Song Saa.



ព្រៃនៅតំបន់កោះរ៉ុង គឺជាជម្រកសម្រាប់ជនជាតិដើមភាគតិច និងជាជម្រកសម្រាប់សត្វគ្រប់ប្រភេទដែលបានមករស់នៅទីនេះ រួមមានសត្វកេងកង

The forests of the Koh Rong archipelago are home to numerous indigenous species, including the oriental-pied hornbill (pictured).



ផ្កាថ្មប៉ប្រះទឹកនៃប្រជុំកោះរ៉ុងមានប្រភេទផ្កាថ្មប៉ប្រះទឹកល្អបំផុតនៅតំបន់ទន្លេមេគង្គក្រោមៗ រដ្ឋាភិបាលអង្គការមិនមែនរដ្ឋាភិបាលកំពុងតែធ្វើការអភិរក្សប្រព័ន្ធអេកូឡូស៊ីទាំងនេះសម្រាប់អនាគតដ៏រីករាយរបស់ក្មេងៗជំនាន់ក្រោយ

The coral reefs of the Koh Rong archipelago are some of the best reef habitats in the lower Mekong region.  Government andnon-government organisations are working to conserve these ecosystems for future generations to enjoy.

តាមរយៈការអប់រំបរិស្ថានអាជ្ញាធររដ្ឋា
ភិបាលនិងអង្គការមិនមែនរដ្ឋាភិបាល
ធ្វើការដើម្បីលើកកំពស់ការអភិរក្ស
បរិស្ថានរាងកាយនៃប្រជុំកោះរ៉ុង

Through environmental education government authorities and non-government organisations work to promote the conservation of the Koh Rong archipelago's physical environments.



សុខភាពសាធារណៈគឺត្រូវបានរង
ឥទ្ធិពលដោយផលប៉ះពាល់នៃការ
ផ្លាស់ប្តូរអាកាសធាតុ។ ការផ្សព្វផ្សាយ
វេជ្ជសាស្ត្រដោយអាជ្ញាធររដ្ឋាភិបាល
និងអង្គការមិនមែនរដ្ឋាភិបាលធ្វើ
ឡើងដើម្បីដោះស្រាយផលប៉ះពាល់
ទាំងនេះតាមរយៈគ្លីនិកសុខភាព
និងបេសកកម្ម

Public health is impacted by the effects of climate change. Medical outreach by government authorities and non-government organisations work to address these impacts through health clinics and missions.



# " ខ្យល់ព្យុះកាន់តែញឹក ទឹកកាន់តែខ្សត់ "

## គម្រោងរូបថតឯកសារ

រូបថតឯកសារគឺជាច្រកទ្វារមួយដែលផ្តល់ទៅកាន់ 'ពិភពលោក' របស់អ្នកថតរូបដែល ផ្តិតយកនូវរូបភាពនិងពាក្យសំដីដែលបង្ហាញពីទស្សនវិស័យនៃភាពលំបាកខុសៗគ្នាទៅឲ្យអ្នកខាងក្រៅបានដឹង។ តាមរយៈរូបភាពដែលបានផ្តិតពីជីវិតជាក់ស្តែងរបស់សហគមន៍អាចនឹងត្រូវបានបរិយាយ ឲ្យដឹងពីផលវិបាក រួមបញ្ចូលទាំង បញ្ហាប្រឈម និងឱកាសតាមរយៈអ្នកថតរូប និងមិត្តភក្តិរបស់ពួកគេ។

## តើធ្វើដូចម្តេចទើបវាមានប្រយោជន៍?

- ការរូបថតឯកសារជាដំណើរការដែលអាចផ្តល់នូវទិដ្ឋភាព និងបង្ហាញពីរបៀបដែលអ្នកថតរូបបានបកប្រែពីពិភពជុំវិញខ្លួនរបស់ពួកគេរួមទាំងបញ្ហាប្រឈម និងការផ្លាស់ប្តូរបរិស្ថានដែលពួកគេបានជួបប្រទះ។
- រូបភាពដែលបានថតនិងរឿងរ៉ាវដែលពួកគេបានសរសេរគឺដើម្បីឲ្យមនុស្សពីជំនាន់មួយទៅជំនាន់មួយបានអាន និងផ្សព្វផ្សាយឲ្យបានកាន់តែច្រើនអំពីបញ្ហាដែលមានរួមបញ្ចូលទាំងការប្រែប្រួលអាកាសធាតុផងដែរ។
- ជាលទ្ធផលនៃការយល់ដឹងពីបញ្ហាអាចត្រូវបានគេប្រើដើម្បីបង្កើតយុទ្ធសាស្ត្រសម្រាប់បង្កើនជីវភាពរស់នៅរបស់ប្រជាជន ហើយជួយក្នុងការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុផងដែរ។
- វាជាជំហ៊ានដែលជួយដល់ប្រជាពលរដ្ឋក្នុងការដោះស្រាយបញ្ហា និងផ្តល់ឥទ្ធិលដល់សហគមន៍មូលដ្ឋាននិងជួយពង្រឹងសង្គមរបស់ពួកគេឲ្យមានភាពប្រសើរឡើងវិញ។
- រូបថតឯកសារនឹងបានផ្តល់ជូននូវការបកស្រាយដែលមានឥទ្ធិពលមួយនិងជាឧបករណ៍ផ្សព្វផ្សាយជាសាធារណៈផងដែរ។

## គម្រោង

នៅខែសីហាឆ្នាំ ២០១៦ មូលនិធិកោះសង្សាបានជួយសម្របសម្រួល ក្នុងការធ្វើការរូបថតឯកសារនៅក្នុងភូមិព្រែកស្វាយ (ប្រជុំកោះរ៉ុង)។ រូបថតឯកសារនេះគឺផ្តោតទៅលើការប្រមូលព័ត៌មានពីគំនិត និងការយល់ឃើញនូវកម្រិតថ្នាក់ភូមិ ស្តីពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងរៀបចំយុទ្ធសាស្ត្រដោះស្រាយដោយសហគមន៍ ដើម្បីគ្រប់គ្រងស្ថានភាពរបស់ពួកគេ។

សិក្ខាសាលាបានធ្វើឡើងរយៈពេលបួនថ្ងៃ ក្នុងនោះមានអ្នកភូមិចូលរួមចំនួនប្រាំបីនាក់រួមមាន បុរស ស្ត្រី យុវជន និងមនុស្សពេញវ័យ គឺជាគ្រូបង្គោលនៃការថតរូប និងការនិទានរឿងនេះ។ យោងតាមសិក្ខាសាលានេះអ្នកភូមិបានចំណាយពេលវេលា ដើម្បីជ្រើសរើសរូបថតដើម្បីរៀបចំជាសាច់រឿងដោយយករូបថតរបស់ពួក គេជាអ្នកប្រាប់ពីដំណើររឿង។ វាជារឿងរ៉ាវទាំងនេះស្ថិតនៅក្នុងបេះដូងនៃសៀវភៅនេះ។ ដូច្នេះសូមស្វាគមន៍មកកាន់ពិភពថ្នាក់ភូមិនៃការប្រែប្រួលអាកាសធាតុ៖ ការកើនឡើងកាន់តែខ្លាំងនៃពិភពងាយរងគ្រោះ "ព្យុះកាន់តែញឹកទឹកកាន់តែខ្សត់"
សូមតាមដានសាច់រឿងរូបថតដូចខាងក្រោម

# The "More Storms and NO WATER"

## Photo-documentary Project

A photo-documentary offers a doorway into the 'world' of the photographer, with images and words yielding perspectives that are otherwise difficult for an 'outsider' to fathom. Through this medium aspects of community life can be revealed, including the problems, challenges and opportunities faced by the photographer and their peers.

## How is it Useful?

- The photo-documentary process can yield a unique view into how the photographer interprets the world around them, including the challenges and environmental changes they face.
- This allows those viewing the photographs and reading their stories to garner a greater awareness of particular issues, including climate change.
- The resulting understanding can be used to inform strategies for improving people's lives, including coping strategies for managing the effects of climate change.
- This helps to democratise the steps for dealing with the issue, empowering local communities and building their social resilience.
- Photo-documentaries also offer a powerful interpretative and public outreach tool.

## The Project

In August 2016 the Song Saa Foundation coordinated a photo-documentary exercise in the village of Prek Svay (Koh Rong archipelago). Its focus was to garner a village-level perspective on the impacts of climate change, and the coping strategies developed by communities to manage for its consequences.

Starting with a four-day workshop, eight villagers —including men and women, youth and adults— were mentored in the craft of photography and story telling. Following the workshop, villagers were provided with time to collect photographs and to prepare the stories told by their images. It is these stories that lie at the heart of this book.

So welcome to the village-level world of climate change: an increasingly vulnerable world of "more storms and no water."

# Name: Khoua Dany

Place of birth: Prek Svay – Koh Rong

Year of birth: 1995

Job: Prek Svay water catchment committee



" ខ្ញុំចូលចិត្តរស់នៅកោះរ៉ុងព្រោះវាមានបរិស្ថានស្អាតហើយ ប្រជាជននៅទីនេះរាក់ទាក់ជាមួយខ្ញុំ។ ជាការពិតណាស់ខ្ញុំអាច រកទិញគ្រឿងសមុទ្រស្រស់ៗ ហើយមានតម្លៃសមរម្យ! "

"ការប្រើប្រាស់ទឹកគឺជាបញ្ហាប្រឈមធំបំផុតនៅពេលដែលមានការប្រែប្រួលអាកាសធាតុ។ ក្នុងអំឡុងរដូវប្រាំងកំដៅកើនឡើងខ្លាំងវាពិតជាមានការលំបាកណាស់សូម្បីតែការរស់នៅក្នុងផ្ទះ ហើយយើងត្រូវការចំណាយលុយកាក់សម្រាប់ទិញទឹកដែលមានតម្លៃថ្លៃជាងមុន។ ការដែលមិនខ្ជះខ្ជាយទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃវាអាចជួយសន្សំលុយខ្ញុំ និងកាត់បន្ថយក្នុងការចំណាយផងដែរ "

*"I love living in the Koh Rong Archipelago, the environment is stunning and the people are kind and friendly. And of course, I can always buy seafood at a reasonable price!"*

*"In the face of climate change water availability is the biggest challenge. During the dry season, when the heat is intense, it is difficult to even stay at home; and we always need to pay for drinking water, which becomes expensive. By reducing the amount of water used during daily activities I can reduce my expenses."*



ក្នុងនាមជាម្តាយវ័យក្មេងម្នាក់ បញ្ហាដែលដានីបារម្ភណ៍មុនគេនោះគឺសុខភាពកូនរបស់នាង។ រឿងរ៉ាវរបស់នាងគឺផ្តោតទៅលើការប្រើប្រាស់ទឹកឡើងវិញនៅក្នុងសកម្មភាពផ្សេងៗគ្នាដូច្នេះនាងអាចមានលុយគ្រប់គ្រាន់ដើម្បីការចំណាយលើការទិញទឹកផឹក។

As a young, single mother, Dany's primary concern is the health of her child. Her story focuses on her efforts to re-use water in different daily activities, so that she can save sufficient money to purchase water for drinking.

# ដានី១.

នៅពេលដែលទឹកភ្លៀងធ្លាក់មិនរទៀងទាត់ ខ្ញុំត្រូវការគិតគូរអោយបានល្អិតល្អន់ហើយត្រូវធ្វើផែនការទុកជាមុនសម្រាប់ត្រៀមក្នុងការខ្វះខាតទឹកនាពេលខាងមុខ ទោះបីជានៅរដូវវស្សាក៏ដោយ។

# Dany 1.

With rainfall becoming more unpredictable, I need to consider and pre-plan for upcoming shortages, even throughout the rainy season.

## ដានី២.

.ទឹកអាចប្រើប្រាស់បានច្រើនដងមុនពេលយើងចាក់វាចោល។ ឧទាហរណ៍ពេលដែលខ្ញុំលាងអង្ករខ្ញុំ
អាចប្រមូលទឹកដាក់ទៅក្នុងផុងផ្សេងទៀត។

## Dany 2.

Water can be used for several purposes before it is drained away. For instance, when I rinse the rice, I can collect the water in another basin…





## ដានី៣.

ទឹកដែលលាងអង្កររួចយកមកលាងសម្អាតបន្លែនិងផ្លែឈើម្តងៗ

## Dany 3.

. … and use it to clean fruit and vegetables.



## ដានី៤.

បន្ទាប់ពីប្រើប្រាស់ច្រើនដងរួច, ខ្ញុំយកទឹកនោះទៅស្រោចបន្លែ និងរុក្ខជាតិផ្សេងៗ។

## Dany 4.

After many uses, I can water the plants with what remains.



# Name: Thou Sokhem

Place of birth: Kampot province
Year of birth: 1983
Job: Teacher

*“គ្រោះរាំងស្ងួត និងកំណើនកំដៅនៅចុងនៃរដូវប្រាំងវាមានផលប៉ះពាល់យ៉ាងច្បាស់ ក្នុងការប្រែប្រួលអាកាសធាតុសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកយើង ប៉ុន្តែខ្យល់ព្យុះខ្លាំងវាក៏មានផលប៉ះពាល់ដល់ប្រជុំកោះរ៉ុងនារដូវវស្សាផងដែរ។ ខ្ញុំត្រូវការធ្វើដំណើរជារៀងរាល់ថ្ងៃពីភូមិព្រែកស្វាយទៅភូមិដើមថ្កូវ ដើម្បីទៅបង្រៀនសិស្ស ហើយលក្ខខណ្ឌអាកាសធាតុវាបានធ្វើឲ្យខ្ញុំមានផលវិបាកក្នុងការធ្វើដំណើរទៅបង្រៀនសិស្ស។ សព្វថ្ងៃនេះយើងទាំងអស់គ្នាត្រូវការទឹកស្អាតជាមួយនឹងការខ្វះខាតទឹកដែលបានជួបប្រទះនៅរដូវវស្សាគឺភ្លៀងធ្លាក់យឺត( ពន្យាពេលវាលា) ហើយទំនិញមួយចំនួនមានការឡើងថ្លៃ ដោយសារតែមានការលំបាកក្នុងការដាំបន្លែ និងការចិញ្ចឹមសត្វ។ អាកាសធាតុក្តៅខ្លាំងគឺគំរាមកំហែងដ៏ធំមួយសម្រាប់ការចិញ្ចឹមសត្វយើងត្រូវការជំនួយផ្នែកបសុពេទ្យបន្ថែមទៀត ដូច្នេះហើយវាធ្វើអោយតំលៃសាច់សត្វមានការឡើងថ្លៃ ដែលជាហេតុធ្វើឲ្យខ្ញុំមានការពិបាកក្នុងការទិញសាច់សម្រាប់គ្រួសាររបស់ខ្ញុំ”។*

*“The drought and extreme heat at the end of the dry season are the clearest impacts of climate change on our daily lives, as well as the heavy storms that can hit the archipelago in the rainy season. Every day I am required to travel from Prek Svay to Daem Thkov to reach the school and with harsh weather conditions it can be difficult.*
*We all need more clean water for drinking and for showering. With the lack of water that we experience when the rainy season is delayed, some food becomes more expensive due to the difficulties in growing vegetables, maintaining gardens and rearing livestock. Extreme temperatures are a major threat for farm animals, resulting in more calls for veterinary assistance. This increases the cost of the meat, making it more difficult for me to purchase it for my family.”*

*រឿងរបស់សុខែមត្រូវបានគូសបញ្ជាក់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុជាញឹកញាប់: ជីវិតក្នុងការចិញ្ចឹមសត្វ។ មិនត្រឹមតែកសិករទេប៉ុន្តែសហគមន៍ទាំងមូលត្រូវបានរងផលប៉ះពាល់តម្លៃសាច់បានកើនឡើងខ្ពស់ផងដែរ។*

Sokhem’s story underlines an often underrated impact of climate change: the life of farm animals. Not only the farmers, but the entire community is affected as the price of meat increases.



## សុខេម១.

ព្យុះខ្លាំងជាងមុនកំពុងតែកើតឡើងជាញឹកញាប់ វាបង្កើតជាបញ្ហាសម្រាប់អ្នកដែលចិញ្ចឹមសត្វ។ ឧទាហរណ៍ : សត្វបក្សីនៅក្នុងទ្រុងបក្សីរបស់ខ្ញុំចាំបាច់ត្រូវធ្វើជម្រកឲ្យល្អជាងមុនដើម្បីការពារពេលមានភ្លៀងខ្លាំង។

## Sokhem 1

Bigger storms are becoming more frequent, creating problems for those raising animals. For instance, the birds in my bird house need to find better shelter when the rain is heavy.



## សុខេម២.

ជារឿយៗខ្ញុំឃើញទ្រុងសត្វមួយចំនួនមានការបាក់បែកដោយសារខ្យល់ព្យុះ។ វាមានន័យថា កសិករសល់តែទ្រុងទទេនៅពេលដែលមានភ្លៀងហើយ។

## Sokhem 2.

I often see animal cages being ripped open by storms. Sometimes this means that the farmer will find the cage empty when he comes back after the rain.



# សុខេម៣.

ប្រសិនបើក្នុងអំឡុងរដូវប្រាំងខ្យល់ក្តៅពេកហើយមិនមានទឹកគ្រប់គ្រាន់ សត្វមាន់និងទាជាច្រើនងាប់ដោយសារតែបញ្ហានេះនៅសល់តែទ្រុងទទេ។ ក្នុងអំឡុងរដូវប្រាំងមុននេះសត្វចិញ្ចឹមរបស់អ្នកជិតខាងខ្ញុំងាប់អស់ច្រើន។

# Sokhem 3

If during the dry season the air gets too hot and there is not enough water, many chickens and ducks die, leaving the cages empty. During the last dry season my neighbour lost the vast majority of his animals.



## សុខែម៤.

ដោយសារតែវាមានផលពិបាកក្នុងការចិញ្ចឹម, មានអ្នកខ្លះបានសម្រេចចិត្តបោះបង់ការចិញ្ចឹមសត្វខ្នាតធំ និងរក្សាទុកសត្វមួយចំនួនសម្រាប់តែការផ្គត់ផ្គង់ប្រចាំថ្ងៃប៉ុណ្ណោះ។

## Sokhem 4.

Because of the harsh working conditions, some of us decide to give up on farming larger farms and keep only a few animals for household supply.



## សុខេម៥.

ប៉ុន្តែមានអ្នកខ្លះបានសម្រេចចិត្តសាងសង់ទ្រុងអោយល្អជាងមុនដើម្បីការពារសត្វពីភ្លៀងធ្លាក់ខ្លាំងនិងកំដៅព្រះអាទិត្យ។ វាមានតម្លៃកាន់តែថ្លៃហើយខ្ញុំមិនប្រាកដថាទ្រុងនេះដំណើរការឬអត់នោះទេប៉ុន្តែវាជាតម្លៃនៃការព្យាយាម។

## Sokhem 5.

Others decide to build better shelters, which are able to protect their farm animals from heavy rains and hot sun. It is more expensive and we are unsure if it will work, but it is worth a try.

# Name: Nget Vanny

Place of birth: Kampot province

Year of birth: 1964

Job: Farmer



"ខ្ញុំបានផ្លាស់ប្តូរទីលំនៅមកទីនេះក្នុងឆ្នាំ ២០១២ ទោះជាយ៉ាងណាក៏ដោយ, ខ្ញុំនឹងមិនត្រឡប់ទៅរស់នៅដីគោកវិញទេ។ ទោះបីជាពេលខ្លះមានការលំបាកជាមួយអាកាសធាតុក៏ដោយ, ប៉ុន្តែខ្ញុំគិតថាវាមានសភាពដូចគ្នានៅទូទាំងប្រទេសកម្ពុជា។ អ្វីដែលមានភាពខុសគ្នានោះគឺបរិស្ថាននៅទីនេះគឺវាល្អប្រសើរហើយគ្រួសាររបស់ខ្ញុំមានការងារធ្វើនៅទីនេះ□

*"I've only moved here in 2012, however, even if I could, I would not return to the mainland. Even though weather conditions are sometimes hard, I think it is the same all over Cambodia. The difference is that the environment here is much better and my family has more work."*

"ខ្ញុំគឺជាកសិករយូរមកហើយ ខ្ញុំអាចនិយាយថាអាកាសធាតុពិតជាមានការប្រែប្រួល ហើយវានៅតែមិនអាចទាយទុកជាមុនបាន។ វាមានការងឿងឆ្ងល់ដែរដែលមានខ្យល់ព្យុះ និងភាពរាំងស្ងួតនៅពេលតែមួយ រឿងទាំងពីរនេះគឺជាបញ្ហាពិតប្រាកដសម្រាប់ការងាររបស់ខ្ញុំ។ នៅពេលដែលមានខ្យល់ព្យុះខ្លាំងខ្ញុំដេកមិនលក់ទេព្រោះខ្លាចខ្យល់បក់រលំផ្ទះ។ ខ្ញុំមានការផ្លាស់ប្តូរវិធីសាស្ត្រដាំដុះរបស់ខ្ញុំហើយខ្ញុំពិតជាមានការងារកាន់តែរវល់ជាងមុន។ ឥឡូវនេះខ្ញុំត្រូវតែដាំដំណាំដាក់ក្នុងធុង ដើម្បីការពារកុំឱ្យលិចទឹកហើយខ្ញុំព្យាយាមស្វែងរកពូជបន្លែថ្មីដែលមានភាពធន់និងការប្រែប្រួលអាកាសធាតុ"

*"I have been a farmer for a long time and I can tell that the weather has changed. It is confusing to have storm and drought at the same time, as both are a real problem for my work. When bigger storms hit the village I worry that my house may collapse, and I cannot sleep. I had to change my cultivation systems as well, so now I plant seeds in buckets to prevent the saplings from drowning, and I am trying to find other vegetables that can survive the drought or heavy rains."*



ក្នុងនាមជាកសិករខ្នាតតូចម្នាក់នៅលើកោះរ៉ុង   គឺវាមានការប្រឈមមួយចំពោះមុខរបរ។   វណ្ណីបានសម្រេចចិត្តក្នុងការចែករំលែកការលំបាកប្រចាំថ្ងៃរបស់គាត់ប៉ុន្តែវាជាផលវិជ្ជមួយដែលការបន្សាំរបស់គាត់ទទួលបានជោគជ័យ។

Being a small-scale farmer on the Koh Rong Archipelago is becoming a challenging job. Vanny decided to share her daily difficulties, but with a positive outlook on successful adaptations.

## វណ្ណី១

នៅពេលដែលមានភ្លៀងខ្លាំងមានកាកសំណល់សំរាមជាច្រើនបានហូរចូលទៅអណ្តូងដែលនាំអោយទឹកកខ្វក់។

## Vanny I.

When intense rains come, a lot of sand is washed into the wells and the water sometimes becomes unclear and dirty.



## វណ្ណី ២.

ក្នុងអំឡុងពេលរដូវវស្សានេះ ខ្ញុំរំពឹងថាសួនបន្លែរបស់ខ្ញុំនឹងមិនមានទឹកជន់លិចទៀតនោះទេ ។ បន្លែមួយចំនួនរបស់ខ្ញុំមិនអាច
ស្រោចស្រង់បានទេ ដូច្នេះហើយខ្ញុំមិនអាចដាំពួកវាដោយផ្ទាល់នៅលើដីបានទេ។

## Vanny 2.

During the wet season I now expect my garden to get flooded from time to time.
Some of my vegetables would not survive, so I cannot plant them directly into the ground.



## វណ្ណី ៣.

ពីមុនខ្ញុំធ្លាប់ដាំត្រកួនពេញមួយឆ្នាំ, ប៉ុន្តែឥឡូវនេះខ្ញុំអាចដាំវាបានតែនៅរដូវវស្សាទេព្រោះវាមានទឹកច្រើន ប៉ុន្តែនៅរដូវប្រាំងវិញឥឡូវនេះខ្ញុំមិនអាចដាំវាបានព្រោះវាទាមទារទឹកច្រើនសម្រាប់ធ្វើការលូតលាស់ហើយខ្ញុំមិនមានទឹកគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ និងស្រោចស្រពនោះទេ។

## Vanny 3.

I used to grow some vegetables all year long. Now I can only plant some of them in the rainy season, as too much water is required to grow them in the dry season, when we no longer have enough.



## វណ្ណី ៤.

មួយឆ្នាំកន្លងមកហើយដែលខ្ញុំចាប់ផ្តើមប្រើរានហាលក្នុងការបណ្តុះដំណាំដើម្បីបញ្ចៀសពួកវាកុំអោយលិចទឹកនៅពេលមានភ្លៀងធ្លាក់ខ្លាំងនៅរដូវវស្សា។ ដូចគ្នានេះផងដែរ, ការប្រើប្រាស់ធុងគឺជាវិធីល្អមួយក្នុងការសន្សំសំចៃទឹកនៅពេលដែលអាកាសធាតុរាំងស្ងួត។

## Vanny 4.

One year ago I started using an overhead platform to grow some of the saplings,—to prevent them drowning during the heavier rains of the wet season. Also, growing in buckets is a good way to save water when the weather becomes too dry.



## វណ្ណី ៥.

វណ្ណី 5. ក្នុងនាមជាកសិករម្នាក់ខ្ញុំដឹងថាការប្រមូលផលរបស់ខ្ញុំពឹងផ្អែកលើរដូវកាលលែងមានភាពទៀងទាត់ហើយ។ ខ្ញុំត្រូវការរកវិធីសាស្រ្ត ដើម្បីរក្សានូវការចំណាយរបស់ខ្ញុំអោយអស់តិចនិងប្រើប្រាស់សម្ភារកែឆ្នៃ សម្រាប់សួនបន្លែរបស់ខ្ញុំវាអាចជួយខ្ញុំសន្សំប្រាក់បានមួយផ្នែក។

## Vanny 5.

As a farmer I know that my harvest relies on the seasons, which are not regular anymore. I need to find new ways to keep my expenses low. Recycling materials for my garden helps me to save money.



## វណ្ណី ៦.

ដើមម្រុំត្រូវបានគេស្គាល់ទូទាំងប្រទេសកម្ពុជាហើយវាត្រូវបានប្រើដើម្បីបន្ថែមរសជាតិទៅក្នុងសម្ល ប៉ុន្តែយើងបានរកឃើញដែរថាវាជាប្រភេទដំណាំដែលអាចបន្សាំខ្លួននៅពេលមានភាពរាំងស្ងួត។

វាជាការសំខាន់ណាស់សម្រាប់ខ្ញុំក្នុងការស្វែងរកបន្លែដែលត្រូវការទឹកតិចដូច្នេះពេលនេះខ្ញុំបានចាប់ផ្តើមដាំដើមម្រុំជាលក្ខណៈខ្នាតតូច។ នាពេលបច្ចុប្បន្ននេះខ្ញុំបានត្រឹមតែចំអិនសម្រាប់ខ្ញុំតែប៉ុណ្ណោះ ប៉ុន្តែជាញឹកញាប់មានអ្នកភូមិមកសុំដើម្បីធ្វើម្ហូប ដូច្នេះខ្ញុំសង្ឃឹមថានាពេលអនាគតខ្ញុំនឹងអាចដាំបន្ថែមទៀតសម្រាប់គ្រួសារខ្ញុំនឹងលក់នៅក្នុងភូមិ។

## Vanny 6.

The moringa tree is known throughout Cambodia, as it is used to add flavour to soups, but we have also found that this plant does not die during droughts. It is very important for me to find vegetables that need less water, so I have recently started a small plantation of moringa. At present I only use it for myself, but often villagers come and ask for it, so I hope that in the future I will be able to grow more of it and sell it to other villagers.

# Name: Vong Samnang

Place of birth: Sihanoukville

Year of birth: 2000

Job: Student



" ការរស់នៅភូមិព្រែកស្វាយគឺជាការល្អមួយសម្រាប់រូបខ្ញុំព្រោះនៅទីនេះសាលារៀននៅជិតផ្ទះ និងមានឱកាសទៅសិក្សាជារៀងរាល់ថ្ងៃ។ លើសពីនេះទៀតខ្ញុំមានមិត្តភក្តិនៅទីនេះច្រើនហើយខ្ញុំមិនចង់ត្រឡប់ទៅដីគោកវិញទេ "

*"Living in Prek Svay is good for me as I live close to the school and have the opportunity to study every day. Also, all of my friends are here and I wouldn't like to go back to mainland and leave them behind."*

"ជារៀងរាល់ឆ្នាំនៅរដូវវស្សាតែងតែធ្លាក់ភ្លៀងយឺត ធ្វើឱ្យចុងរដូវប្រាំងអូសបន្លាយកាន់តែវែងបន្ថែមទៀតហើយមានការប្រឈមជាមួយនឹងបញ្ហាកាន់តែច្រើនប៉ុន្តែនៅពេលជាមួយគ្នានេះដែររដូវវស្សានាំមកនូវខ្យល់ព្យុះជាច្រើនឹងកាន់តែខ្លាំងថែមទៀត។ នៅចុងនៃរដូវប្រាំងមិនបានកាត់បន្ថយទេ។ ជំនួសមកវិញកំដៅមានការអូសបន្លាយដែលយើងគ្រប់គ្នាកំពុងជួបប្រទះ វាគឺជាការលំបាកមួយសូម្បីតែការរស់នៅប្រចាំថ្ងៃដូចជាការដេក ដើរនិងអង្គុយនៅក្នុងថ្នាក់រៀនក៏ពិបាកដែរ"។

*"Every year the rainy season comes a little later, making the end of the dry season difficult to handle, but, at the same time, the wet season brings more storms than it used to and they are getting stronger.*
*The final part of the dry season is the most difficult time of the year and it is hard to even carry out basic daily activities such as sleeping, walking and sitting in the classroom, all because of the heat."*



រឿងរបស់សំណាងផ្តោតទៅលើការកើនឡើងនៃខ្យល់ព្យុះខ្លាំងក្នុងរដូវវស្សានិងមានការពិបាកទស្សន៍ទាយអំពីលក្ខខណ្ឌបរិស្ថាន។

Nang's story focuses on the increasing number of storms across the wet season and the uncertainty of environmental conditions.

## សំណាង ១

កម្រិតទឹកនៅជុំវិញភូមិកើនឡើងជាលំដាប់ដោយមិនអាចទាយទុកជាមុនបាន។ ពេលខ្លះកម្រិតទឹកទាបជាងអ្វីដែលធ្លាប់មានពីមុនមក ប៉ុន្តែនៅពេលដែលមានភ្លៀងធ្លាក់ខ្លាំងដែលអាចបណ្តាលអោយមានបាក់ដីខ្សាច់។

## Nang 1.

Water levels around the village are becoming more unpredictable. Sometimes water levels are much lower than they should be, but when heavy rains come, the storms are so strong that they wash away the stream bank.



# សំណាក ២

*សំណឹកផ្លូវទឹកជាមូលហេតុធ្វើឲ្យមានអោយលក្ខខណ្ឌអាក្រក់សម្រាប់ព្រៃកោងកាងដែលដុះលូតលាស់នៅលើឆ្នេរខ្សាច់។*

## Nang 2.

The erosion of the waterways creates poor growing conditions for the mangroves that grow in the sand.



# សំណាង ៣

ខ្យល់ព្យុះខ្លាំងគឺកើតឡើងជាញឹកញាប់បន្ថែមទៀត និងមានព្យុះខ្លាំងជាងមុនហើយភ្លៀងធ្លាក់ខ្លាំងជាងមុន។
ទឹកពេលខ្លះវាហូរយ៉ាងលឿនដូច្នេះវាបាក់ដីបណ្ដាលឱ្យដើមឈើដួលរលំ ជាហានិភ័យចម្បងសម្រាប់អ្នកភូមិ។

# Nang 3.

Bigger storms are becoming more frequent and with them come heavier rains. Water sometimes flows so fast that it washes away the soil, causing trees to fall down. This creates problems for the people living in the Prek Svay.

# សំណាក ៤

ខ្យល់ព្យុះខ្លាំងធ្វើអោយដំបូលផ្ទះចាស់ៗរបើកៗ

## Nang 4.

Storms may also be strong enough to remove the roofs off buildings.





## សំណាង ៥

ជួនកាលអាកាសធាតុអាចប៉ះពាល់ដល់ជីវិតរស់នៅប្រចាំថ្ងៃរបស់សហគមន៍ដែលធ្វើឱ្យការងាររស់នៅប្រចាំថ្ងៃជាមានការលំបាកច្រើនជាងមុនៗនេះជាបញ្ហាធំជាពិសេសសម្រាប់កុមារនិងបុរសចាស់ៗ

## Nang 5.

At times weather can impact the daily lives of the community, making even ordinary tasks more difficult. This is a big problem, especially for children and older people.

# Name: Kou Lykeav

Place of birth: Prek Svay – Koh Rong

Year of birth: 2003

Job: Student



"ខ្ញុំស្រឡាញ់ភូមិព្រែកស្វាយខ្លាំងណាស់។ ខ្ញុំមានមិត្តភក្តិនៅទីនេះហើយយើងរស់នៅជាមួយបរិស្ថានស្រស់ស្អាត។ ខ្ញុំចូលចិត្តទៅសាលារៀននៅទីនេះ ជាកន្លែងដែលខ្ញុំរៀនរាល់ថ្ងៃហើយការរៀននៅទីនេះពុំមានការបង់ប្រាក់សម្រាប់ការសិក្សានិងសម្ភារៈអប់រំឡើយ

*"I love Prek Svay so much. I have plenty of friends here and we live in a beautiful place. I really like going to school here, where I can go every day without paying for anything."*

"ខ្ញុំក្មេង ហើយវាមិនមែនជាការងាយស្រួលទេសម្រាប់ខ្ញុំ ក្នុងការធ្វើការប្រៀបធៀបជាមួយនឹងអាកាសធាតុដែលធ្លាប់មានពីមុនមក ខ្ញុំដឹងថាទឹកអាចនឹងមានការខ្វះខាតហើយការខ្វះខាតទឹកវាអាចកើតឡើងនៅពាសពេញសហគមន៍របស់យើង។ ខ្ញុំនៅតែអាចផ្តល់និងជួយដល់ក្រុមគ្រួសាររបស់ខ្ញុំសម្រាប់ការផ្គត់ផ្គង់ទឹកទោះបីជាឥឡូវនេះខ្ញុំត្រូវធ្វើការពិបាកជាងមុនក៏ដោយ។ ដូច្នេះហើយដោយសារតែកិច្ចខិតខំប្រឹងប្រែងដើម្បីយកទឹកប្រើជាញឹកញាប់វាធ្វើអោយខ្ញុំមានការយឺតយ៉ាវក្នុងកាទៅសាលារៀនហើយនាងខ្ញុំគឺជាមនុស្សចូលចិត្តការរៀនសូត្រណាស់ខ្ញុំមិនចង់មានអវត្តមានទេ។

*"I am young and it is not easy for me to make a comparison with the climate we had before, yet I realise that water in our community can be scarce. I am still able to bring water to my family. However, I do need to work harder than I have done in the past to do this. Because of the increased effort to get water, I am often late for school, which bothers me as I enjoy my classes and I don't like to miss them.*



យុវជនវ័យក្មេងជារឿយៗតែងតែជួយផ្គត់ផ្គង់ទឹកដល់គ្រួសារ។ លីគាវ បង្ហាញពីទម្លាប់របស់នាងក្នុងការចូលរួមក្នុងការងារផ្ទះ នៅពេលភ្លៀងធ្លាក់មិនទៀងទាត់, សូម្បីតែនៅក្នុងរដូវវស្សាក៏អាចនឹងមានបញ្ហាប្រឈមផងដែរ។

Young adults are often in charge of collecting a family's daily water. Lykeav shows her routine for completing the task, which because of changing rainfall patterns has become more difficult.

# លី គាវ ១.

ប្រជាជនភាគច្រើននៅក្នុងភូមិដែលមិនមានអណ្តូងទឹកផ្ទាល់ខ្លួន ការដើរទៅដងទឹកយកមកប្រើប្រាស់គឺជាការងារប្រចាំថ្ងៃរបស់ពួកគេ

# Ly keav 1.

For the majority of the people in the community, who do not own a private well, walking some distance to get water is a daily routine.

# លី គាវ ២.

*នៅអំឡុងពេលមានភ្លៀងធ្លាក់ខ្លាំងទឹកហូរបាននាំដីខ្សាច់និងកំទេចស្លឹកឈើធ្លាប់ចូលទៅក្នុងអណ្តូងទឹកនៅក្នុងភូមិ។ ដែលយើងឃើញថាទឹកមានភាពកខ្វក់។*

# Lykeav 2.

During storms water overflows onto the ground, bringing sand and dead leaves back into the well, which makes the water dirty.





## លី គាវ ៣.

ការរក្សារទឹកទុកចោលក្នុងធុងមួយរយះពេលវាជួយឱ្យទឹកថ្លាស្អាត, ដែលដីទាំងនោះវាបានកកនៅបាតធុងៗ

## Lykeav 3.

Leaving water in the buckets for a while helps us to make it cleaner, with the dirt settling on the bottom.



## លី គាវ ៤.

ដោយសារតែភ្លៀងធ្លាក់មិនអាចទុកចិត្តបានតម្រូវឱ្យយុវជនវ័យក្មេងនៅក្នុងសហគមន៍ធ្វើការងារច្រើនហើយពេលខ្លះ
មានការបាក់ទឹកចិត្តក្នុងការរៀនសូត្រទៀតផង។

## Lykeav 4.

The changing rains are hard for people my age because we have to help out and it takes us away from our studies.



## លីគាវ ៥.

បញ្ហាប្រឈមទាក់ទងនឹងការប្រែប្រួលអាកាសធាតុវាជាឱកាសមួយជំរុញអោយអ្នកភូមិទាំងអស់មានកិច្ចសហការគ្នាផងដែរ។

## Lykeav 5.

The challenge of climate change also creates opportunities for cooperation.

# Name: Chan Sarin

Place of birth: Kandal Province

Year of birth: 1958

Job: Solid waste management committee – Prek Svay



"ខ្ញុំបានផ្លាស់ប្តូរមករស់នៅកោះរ៉ុងនេះនៅក្នុងឆ្នាំ ១៩៩០ ដូច្នេះខ្ញុំឃើញមានការផ្លាស់ប្តូរជាច្រើននៅទីនេះ។ ពេលខ្ញុំទៅដីគោកម្តងៗខ្ញុំឃើញមានផ្សែង និងការបំពុលយ៉ាងធ្ងន់ធ្ងរ ហើយខ្ញុំមិនសូវសប្បាយជាមួយនិងបរិស្ថានដូចដែលខ្ញុំរស់នៅលើកោះនោះទេ។ ព្រៃឈើ និងសមុទ្រវាធ្វើឱ្យកន្លែងនេះកាន់តែពិសេសជាមួយនឹងខ្យល់បរិសុទ្ធ ហើយអ្នកអាចដកដង្ហើមបានស្រួល! នៅភូមិព្រែកស្វាយ ខ្ញុំមានការងារល្អមួយ ហើយខ្ញុំមានដីមានផ្ទះផ្ទាល់ខ្លួនរបស់ខ្ញុំចំនែកកូនៗរបស់ខ្ញុំបានទទួលការអប់រំគ្រប់ៗគ្នានៅទីនេះ។ នៅលើកោះនេះគឺជាកន្លែងដែលខ្ញុំហៅថាជា ភូមិដ្ឋានរបស់ខ្ញុំ"

*"I moved to the Koh Rong archipelago in 1990, so I have witnessed the many changes that have occurred here. When I go to mainland the smog and pollution is very bad and I never enjoy the environment as much as I do here. The jungle and the ocean make this place really special, with as much clean air as you can breathe! In Prek Svay I have a good job, my own property and my children are able to get an education. Here, on the island, is where I call home"*

"នៅក្នុងរយៈពេល ២៦ ឆ្នាំនៃការរស់នៅលើកោះរ៉ុងនេះខ្ញុំទើបតែបានឃើញការផ្លាស់ប្តូរអាកាសធាតុជាលើកដំបូង។ កាលពីមុនរដូវវស្សាគឺមានភ្លៀងធ្លាក់ទៀងទាត់បើមានការយឺតយ៉ាវក៏តិចថ្ងៃដែរប៉ុន្តែឥឡូវនេះគឺយើងមិនអាចព្យាករណ៍នៃការធ្លាក់ភ្លៀងបានទៀតឡើយហើយរដូវធ្លាក់ភ្លៀងចេះតែពន្យាពេលយូជាងពីមុន។ភាពរាំងស្ងួតនិងសីតុណ្ហភាពខ្ពស់គឺជាក្តីបារម្ភណ៍ដ៏ធំបំផុតចំពោះខ្ញុំ។ ហេតុអ្វី? ព្រោះខ្ញុំត្រូវចំណាយលុយច្រើនជាងមុនសម្រាប់ទិញទឹកផឹក ហើយខ្ញុំត្រូវការផ្ងូតទឹកញឹកញាប់ជាងពីមុនខ្ញុំធ្លាប់តែរស់នៅត្រជាក់ប៉ុន្តែទោះជាយ៉ាងនេះក្តី ជារៀងរាល់ថ្ងៃគឺខ្ញុំមិនដែលមានអារម្មណ៍ឈឺទេ"។



*"In 26 years on Koh Rong I have seen first-hand the change in the climate. Once, the wet season used to arrive on time. However, now there is no way to predict when the rains will come, but it is always later than it used to be. The drought and the high temperatures are my biggest concern. Why? Because I need to spend more money for drinking water, I need to take more showers than I used to so to stay cool, but even so there are days where you can't help feeling sick."*

*សារិនជាប្រធានគណៈម្ចាធិការគ្រប់គ្រងកាកសំណល់រឹងបង្កើតឡើងនៅភូមិព្រែកស្វាយដើម្បីគ្រប់គ្រងបរិមាណសំរាមទាំងក្នុងភូមិ និងមកពីសមុទ្រ។ រូបថតសាច់រឿងរបស់សារិនគឺបង្ហាញពីការកត់សម្គាល់ពីផលប៉ះពាល់ដ៏កម្រនៃការប្រែប្រួលអាកាសធាតុ ការកើនឡើងនៃចំនួនសំរាមពង្រាយតាមច្រាំងសមុទ្រនៃផ្ទះនៅលើកោះរបស់គាត់ ។*

## សារិន ១.

*សហគមន៍ព្រែកស្វាយបង្កើតគណៈកម្មការគ្រប់គ្រងកាកសំណល់រឹងដើម្បីដោះស្រាយបញ្ហាសំរាម ដែលកើតឡើងនៅក្នុងភូមិនេះប៉ុន្តែមានសំរាមច្រើនទៀតហែលរសាត់មកពីសមុទ្រ។ ទូកដែលចតនៅពីមុខភូមិរបស់យើងបានបោះសំរាមចូលទៅក្នុងសមុទ្រហើយនៅពេលដែលខ្យល់ព្យុះមក វាបាននាំសម្រាមទាំងនោះមកលើឆ្នេរសមុទ្ររបស់យើង។*

## Sarin 1.

The Prek Svay community established a solid waste management committee to handle the trash produced in the village, but more rubbish is coming from the ocean. There are always boats in front of our village, throwing rubbish in the sea and when storms come, this is brought onto our beaches.



## សារិន ២.

ព្យុះផ្តល់នូវបរិមាណយ៉ាងច្រើននៃសំរាមមកលើបណ្តោយឆ្នេរសមុទ្រដ៏ស្រស់ស្អាតនៃប្រជុំកោះរ៉ុងហើយសំរាមភាគច្រើន
សំរាមទាំងនេះមានរយះពេលយូរណាស់ទើបរលាយហើយអាចមានផលប៉ះពាល់អវិជ្ជមានដល់សុខភាពមនុស្ស និងផ្កាថ្ម។

## Sarin 2.

Storms deliver massive quantities of trash along the beautiful coast of the Koh Rong archipelago, the majority of which is plastic. This can stay for a long time and can have negative impacts on people's health and the coral reefs.



## សារិន ៣.

សំរាម និងកំទិចកំទីមងចាស់ៗវារសាត់ទៅជាប់នឹងដើមកោងកាង។ សហគមន៍របស់យើងមិនមានការកាប់ដើមកោងកាងទៀតទេដូចជា ឥឡូវនេះយើងដឹងពីសារៈសំខាន់របស់កោងកាងប៉ុន្តែឥឡូវនេះសំរាមជាបញ្ហាធំបំផុត។

## Sarin 3.

Rubbish and old fishing nets are likely to remain stuck in the mangroves. Our community does not cut mangroves anymore, as we now know how important they are.



**សារិន ៤.**

*ជាអកុសលការកើនឡើងនៃខ្យល់ព្យុះដែលមានទំហំធំវាបាននាំសំរាមប្លាស្ទិចជាច្រើនដែលនៅឆ្ងាយពីឆ្នេរមកដាក់លើឆ្នេរហើយវាធ្វើឱ្យការគ្រប់គ្រងសំរាមមានការលំបាកកាន់តែខ្លាំងឡើង។*

**Sarin 4.**

Unfortunately, more powerful storms push large amounts of plastics beyond the beach, making the management of waste more difficult.



## សារិន ៥.

ជាសំណាងល្អ កុមារក្នុងភូមិកំពុងតែមានការអភិវឌ្ឍក្នុងការយល់ដឹងថ្មីអំពីបរិស្ថានរបស់ពួកគេ។
ពួកគេគឺជាផ្នែកមួយនៃដំណោះស្រាយ។

## Sarin 5.

Luckily, children in the village are developing a new awareness about their environment.
They must be a part of the solution.

# Name: Ngoun Toan



Place of birth: Kampot Province

Year of birth: 1987

Job: Pre-primary Teacher – Prek Svay

"នៅក្នុងឆ្នាំ ២០០៨ ខ្ញុំមានឱកាសដ៏ល្អមួយពីអង្គការក្រៅរដ្ឋាភិបាល ដែលបានសាងសង់សាលាមត្តេយ្យ ខ្ញុំក៏ត្រូវបានគេជ្រើសរើសធ្វើជាគ្រូបង្រៀនម្នាក់។ ការរស់នៅកោះរ៉ុង វាជាក្តីស្រមៃមួយ ហើយខ្ញុំចូលចិត្តបរិស្ថានធម្មជាតិនៅជុំវិញខ្ញុំ ម៉្យាងវិញទៀត ខ្ញុំស្រលាញ់ស្នាមញញឹមរបស់ប្រជាជននៅទីនេះ។ នេះគឺជាមូលហេតុដែលធ្វើអោយខ្ញុំធ្វើជាគ្រូបង្រៀននៅទីនេះ ហើយវាគឺជាឱកាសដ៏អស្ចារ្យមួយសម្រាប់ខ្ញុំក្នុងការជួយក្មេងៗនៅក្នុងភូមិអោយមានភាពរីកលូតលាស់ឡើង "

*"In 2008 I had a great opportunity, from the NGO that built the pre-primary school, to come and work as a teacher. Living in Koh Rong is a dream. I love having the natural environment around me, and I love the smiles of the people. This is why being a teacher here is an amazing opportunity for me, to help the children of the village grow up"*

"អាកាសធាតុពិតជាមានការកើនកំដៅ។ នៅរដូវប្រាំងអាកាសធាតុពិតជាក្តៅខ្លាំង ហើយនៅរដូវវស្សាភ្លៀងធ្លាក់យឺតជាងពីមុន ម៉្យាងទៀតទឹកសាប និងទឹកផឹកកំពុងមានការឡើងថ្លៃ និងពិបាករក។ ជាម្តាយដែលកូនពីរនាក់ក្នុងបន្ទុក ការខ្វះខាតទឹកនិងខ្យល់ព្យុះនៅរដូវវស្សាវាធ្វើអោយខ្ញុំពិបាកចិត្តយ៉ាងខ្លាំង។ បញ្ហានៅត្រង់ថា រដូវកាលទាំងពីរនេះគឺមានការប្រែប្រួលយ៉ាងខ្លាំង ការរស់នៅលើកោះនេះយើងមានការតស៊ូទាំងអស់គ្នាដើម្បីសម្របខ្លួនទៅនឹងអាកាសធាតុ "។

*"The climate is definitely warming. During the dry season it gets really hot and when the rains are delayed, as they have been recently, fresh and drinking water can be expensive or not easily available. As a mother of two children the lack of water scares me a lot, as well as some of the storms during the rainy season. The problem is that both the seasons are changing in different ways, so on the island we have to struggle to adapt."*



ទួនផ្តោតទៅលើបញ្ហាទឹកនិងសារៈសំខាន់នៃការគ្រប់គ្រងធនធាននេះអោយបានល្អ។ទោះបីជាប្រភពនៃការផ្គត់ផ្គង់នៅជិតក៏ដោយ យុទ្ធសាស្ត្រនៃការបន្សុំនិងការសហការគ្នាតែងតែត្រូវការជានិច្ច។ ជាធម្មតាការបន្សុំនេះមានទាំងការស្តុកទឹកមិនថាបានមកពីអណ្តូងរឺ ទឹកភ្លៀងទេ។

Toan focuses on the availability of water and the importance of good management of this resource. Even when the source of supply is nearby, an adaptation strategy and collaboration is needed. Usually, the adaptation consists of storing the water, supplied from a well or rain harvest system.

## ទួន ១.

នៅពេលដែលមិនមានទឹកខ្ញុំត្រូវដើរស្វែងរកទឹកនៅគ្រប់ទីកន្លែងតាមដែលខ្ញុំអាចធ្វើបាន។ ពេលខ្លះខ្ញុំប្រើប្រាស់ទឹកដែលដងមកពីអណ្តូងក្នុងដីដែលជាទឹកមិនស្អាតហើយសំបូរដីខ្សាច់។

## Toan 1.

When water is not available, I need to look for it wherever I can. Sometimes this means taking water from wells on the ground, which is dirty and full of sand.



## ទួន ២.

វាគឺជាការពិតទឹកភ្លៀងធ្វើឱ្យសំបូរទឹកសម្រាប់ប្រើប្រាស់បានយ៉ាងងាយស្រួល, ប៉ុន្តែរដូវកាលនេះគឺមិនទៀងទាត់ដូចដែលអ្វីដែលធ្លាប់មាននោះទេ។ ពេលខ្លះសូម្បីតែនៅក្នុងរដូវវស្សាមានសប្តាហ៍ខ្លះមានជួបប្រទះនឹងគ្រោះរាំងស្ងួត ហើយការរក្សាទឹកទុកវាធ្វើឱ្យខ្ញុំមានអារម្មណ៍សុវត្ថិភាពជាង។ ការរក្សា/ត្រងទឹកទុកគឺជាវិធីល្អមួយក្នុងការបង្រៀនកូនរបស់យើងអោយយល់ពីសារៈសំខាន់នៃការមិនខ្ជះខ្ជាយទឹក។

## Toan 2.

It is true that rains make water more easily available, but the season is not as regular as it used to be. Sometimes, even in the wet season, there are weeks in which it is drier so storing water makes me feel safer. It is also a good way to teach my children the importance of not wasting it.



**ទួន ៣.**

នៅពេលដែលមានលទ្ធភាព, អ្នករាល់គ្នានៅក្នុងភូមិនេះព្យាយាមក្នុងការប្រមូលទឹកភ្លៀងសម្រាប់មុជ,
ផឹកនិងបោកខោអាវ។ជាពិសេសក្រោយពេលដែលមានព្យុះខ្លាំង ធ្វើឲ្យទឹកមានភាពស្អាតជាងទឹកដែលយើងដងមកពីអណ្ដូង។

**Toan 3.**

When possible everyone in the village tries to collect rainwater for cleaning, drinking and washing, especially after strong storms. It is much cleaner than the water in the wells.



# ទួន ៤.

ការថែរក្សាទឹកសម្រាប់ក្រុមគ្រួសាររបស់ពួកយើង វាត្រូវការពេលវេលា និងកំលាំងជាច្រើន។ នៅពេលដែលអាកាសធាតុក្តៅខ្ញុំត្រូវតែមានការប្រុងប្រយ័ត្នមិនត្រូវខ្ជះខ្ជាយទឹកទេ ហើយនៅពេលដែលមានភ្លៀងធ្លាក់ខ្ញុំត្រូវតែធ្វើការប្រមូលទឹកស្អាតតាមដែលអាចធ្វើទៅបាន ដោយការប្រើប្រាស់ធុងទឹក ហើយត្រូវរង់ចាំឱ្យដីរង់នៅបាតធុង ដើម្បីធ្វើឱ្យទឹកថ្លា។

# Toan 4.

Taking care of the water for our family requires a lot of time and energy. When it is hot I must be careful not to waste it. When it is wet I try to store as much clean water as I can, by taking buckets of well water and waiting for the soil to fall to the bottom.



## ទួន ៥.

នៅពេលមានរលកកំដៅឬនៅពេលដែលព្យុះខ្លាំង វាមិនមែនជាការងាយស្រួលឡើយសម្រាប់មនុស្សឈឺដើម្បីទទួលបានទឹកសម្រាប់ប្រើប្រាស់។ ខ្ញុំព្យាយាមអស់ពីសមត្ថភាពដើម្បីជួយផ្តល់ទឹកឲ្យគ្រប់គ្រាន់ដល់សាច់ញាតិណាដែលមិនអាចទៅរកទឹកដើម្បីប្រើប្រាស់សម្រាប់ខ្លួនរបស់ពួកគេផ្ទាល់បាន។

## Toan 5.

During heat waves, or when a big storm is approaching, it is not easy for sick people to get water. I try to bring back enough water for relatives who cannot get it for themselves.



# គម្រោងរូបថតក្រុមការងារ

# មូលនិធិកោះសង្សា

## ហ្វីលិប៉ូ អឹម ខលលី

អ្នកគ្រប់គ្រងគម្រោង
មូលនិធិកោះសង្សា

នៅពេលដែលអ្នកធ្វើការក្នុងការងារអភិរក្ស និងអភិវឌ្ឍន៍សហគមន៍ ការអប់រំគឺជាផ្នែកមួយនៃការព្រួយបារម្ភចម្បងរបស់អ្នក។ ការធ្វើការងារនៅលើរូបថតឯកសារ គឺជាឱកាសមិនគួរឱ្យជឿសម្រាប់ខ្ញុំ ហើយវាគឺជាផ្នែកមួយទៀតនៃដំណើរការរៀនសូត្របន្ថែម។ ក្នុងអំឡុងថ្ងៃសិក្ខាសាលានេះ ខ្ញុំមានឱកាសដើម្បីបានដឹង និងឃើញពីទិដ្ឋភាពទូទៅនៃជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងសហគមន៍ព្រែកស្វាយ ផ្ទះរបស់ពួកគេ ការងាររបស់ពួកគេ និងក្រុមគ្រួសាររបស់ពួកគេ។ ជីវិតប្រចាំថ្ងៃរបស់អ្នកភូមិជាពន្លឺដែលអាចឲ្យខ្ញុំដឹងពីការរស់នៅរបស់ពួកគេ ក្នុងការថតរូប និងសរសេររឿងរ៉ាវដែលពួកគេបានរស់នៅ ។

# The Song Saa Foundation

# PHOTO-DOCUMENTARY TEAM

## Filippo M. Carli

Project Manager
Song Saa Foundation

When you work in conservation and community development, education is one of your main concerns. Working on the photo-documentary was an incredible opportunity for me to be on the other side of the learning process. During the workshop I had the chance to have a privileged view of village life in Prek Svay, the community's houses, their jobs and their families. The daily life of the villagers was brought to me with no filters, in the shape of stories and photography, directly from those who live it.



# គើត ម៉ាត់ត្រហេត

## មន្ត្រី អភិរក្ស និង អភិវឌ្ឍន៍សហគមន៍
## មូលនិធិកោះសង្សា

ខ្ញុំពិតជាមានមោទនភាពដែលបានចូលរួមក្នុងកម្មវិធី រូបថតឯកសារនេះ មុនពេលចូលរួមសិក្ខាសាលា រូបថតឯកសារនេះ ខ្ញុំមិនដឹងថាអ្វីទៅជារូបថតឯកសារនោះទេ ប៉ុន្តែក្រោយពេលចូលរួមសិក្ខាសាលានេះរួចខ្ញុំមានអារម្មណ៍ថាមានការយល់ដឹងកាន់តែច្បាស់ហើយបានយល់អត្ថន័យ ពីអ្វីទៅជាគោលបំណងរបស់រូបថតឯកសារ

# Keut Mattrohet

## Community and Conservation Officer
## Song Saa Foundation

I am proud to have participated in the photo-documentary workshop. Before this experience, I did not know what a photo-documentary is, but after participating actively in the workshop, I feel that I understand much better and grasp its meaning and purpose.

# ការប្រែប្រួលអាកាសធាតុ-
# វិបត្តិនៃអាយុជីវិតរបស់យើង

វាគឺជាការលំបាកក្នុងការគេចចេញពីការប្រែប្រួលអាកាសធាតុ។ តាមរយៈកិច្ចប្រជុំកំពូលជាសកល ដែលបានធ្វើការកត់ត្រានៅលើបណ្តាញអ៊ិនធើណិតបង្ហាញថា"អាកាសធាតុឥឡូវមិនដូចពីមុនទេ" ហើយការបង្ហាញនេះគឺជាការបង្ហាញពីទិដ្ឋភាពជាក់ស្តែងវាមិនមែនបង្ហាញពីអារម្មណ៍ផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់នោះទេ បាតុភូតនេះគឺមិនប្រាកដថាល្អ ឬ អាក្រក់នោះទេ សម្រាប់ជីវិតរស់នៅសព្វថ្ងៃ ដូចនេះវាជាចំនុចមួយដែលត្រូវលើកយកមកធ្វើការជជែកពិភាក្សាគ្នាថា តើវាគឺជាអ្វីអោយពិតប្រាកដ?

ការប្រែប្រួលអាកាសធាតុ គឺជាលទ្ធផលដែលបានមកពីកត្តាសកម្មភាពរបស់មនុស្ស ដោយសារតែការបញ្ចេញឧស្ម័នពុលទៅក្នុងបរិយាកាស។ ឧស្ម័ន "ផ្ទះកញ្ចក់" ទាំងនេះដែលការរួមបញ្ចូលទាំង កាបូនឌីអុកស៊ីត, មេតាន និង នីត្រូអុកស៊ីដ ឧស្ម័នទាំងនោះហើយដែលធ្វើឲ្យសម្ពាធបរិយាកាសកើនកំដៅ ដែលជាហេតុធ្វើឲ្យផែនដីកើនកំដៅ។ ការប្រើប្រាស់ប្រេងឥន្ធនៈហ្វូស៊ីល ដោយការដុតរបស់មនុស្សបានចូលរួមចំណែកមួយយ៉ាងធំដល់ដំណើរការនៃការកើនឡើងនូវកំដៅ ការជាប់ទាក់ទងគ្នានៃការកើនឡើងកំដៅរបស់ភពផែនដី គឺការប្រែប្រួល និងការគំរាមកំហែង។ ការរលាយទឹកកកនៅតំបន់ប៉ូល និងការរលាយបន្តិចម្តងៗ នៃតំបន់វាលអាក់ទិកភាគខាងជើងត្រូវបានគេដឹងរួចទៅហើយ ប៉ុន្តែបញ្ហាចំបង និងធ្ងន់ធ្ងរជាងនេះទៀតនោះគឺផលវិបាកនៃការប្រែប្រួលបរិយាកាសរបស់ផែនដី។

ខ្យល់មូសុងអាស៊ីខាងកើតគឺជាឧទាហរណ៍មួយស្រាប់ក្នុងការនាំយកនូវទឹកភ្លៀង។ ប្រព័ន្ធទឹកភ្លៀងនេះមានសារៈសំខាន់ណាស់សម្រាប់ប្រជាជនស្ទើរតែពាក់កណ្តាលនៃចំនួនប្រជាជននៅលើពិភពលោកដែលពឹងផ្អែកទៅលើវិស័យសេដ្ឋកិច្ចកសិកម្មនៅទ្វីបទាំងប្រាំ។ ការប្រែប្រួលអាកាសធាតុបានបណ្តាលឱ្យអាកាសធាតុមានការផ្លាស់ប្តូរដោយមានភ្លៀងធ្លាក់មិនទៀងទាត់ និងមិនញឹកញាប់ និងការរងនូវការបំផ្លាញដោយសារខ្យល់ព្យុះញឹកញាប់ ។ ក្រៅពីប៉ះពាល់ដល់មនុស្ស វាក៏មានផលប៉ះពាល់ដល់ជីវិតរុក្ខជាតិ និងសត្វ ក្នុងការធ្វើការបំលាស់ទី និងបន្តពូជ។ ហើយហានិភ័យដែលបានកើតឡើង មនុស្ស សត្វ និងរុក្ខជាតិទាំងនោះគឺមិនអាចសម្របខ្លួនជាមួយនឹងអាកាសធាតុថ្មីនេះបានទេ។

## ការប្រែប្រួលអាកាសធាតុ និងសមុទ្រ

ពួកយើងនៅតែព្យាយាមស្វែងយល់ពីផលលំបាកនៃការប្រែប្រួលអាកាសធាតុនៅតំបន់សមុទ្រទូទាំងពិភពលោក។ ការរលាយទឹកកក និងការកើនឡើងកំដៅ វាបាន

ចូលរួមចំណែករួចទៅហើយក្នុងការធ្វើអោយកម្ពស់ទឹកសមុទ្រមានការកើនឡើង ប៉ុន្តែផលប៉ះពាល់ផ្សេងៗទៀត គឺឲ្យមានការគួរឱ្យព្រួយបារម្ភដែរ។

ផ្កាថ្មដែលប្រែពណ៌នៅជាពណ៌ស គឺជាបញ្ហាមួយដែលកើតឡើងនៅពេលពួកប្រូតូសូអ៊ែដែលរស់នៅពឹងផ្អែកលើផ្កាថ្មហើយសំយោគពន្លឺព្រះអាទិត្យជាអាហារត្រូវបានចាកចេញពីផ្កាថ្មដោយសារតែឥទ្ធិពលកំដៅនៅទីនោះកើនឡើង ដែលជាលទ្ធផល វាធ្វើអោយផ្កាថ្មចេញរូបរាងប្រែជាពណ៌សហាក់ដូចជាមានជំងឺ។ អរគុណណាស់សម្រាប់ពិភពផ្កាថ្ម ដែលផ្កាថ្មប្រែពណ៌ទៅជាពណ៌ស ហើយវាមិនងាប់ប៉ុន្តែការលូតលាស់របស់ពួកគេត្រូវរង់ចាំរហូតដល់ប្រូតូសូអ៊ែអាចវិលត្រឡប់មករស់នៅលើផ្កាថ្មវិញ។ ខណៈពេលដែលការរង់ចាំនេះវាបណ្តាលឲ្យត្រី និងសត្វផ្សេងទៀត ដែលពឹងផ្អែកលើផ្កាថ្មសម្រាប់សុខុមាលភាពរបស់ត្រី និងសត្វ នឹងប្រឈមមុខ នឹងការមិនលូតលាស់ឬបាត់បង់ជីវិត។ ការជាប់ទាក់ទងនេះគឺជាអន្តរអំពើនៃខ្សែសង្វាក់ប្រព័ន្ធអេកូឡូស៊ី ហើយទីបំផុតផលប៉ះពាល់នេះធ្លាក់មកលើអ្នកភូមិ ដែលពឹងផ្អែកលើតំបន់ផ្កាថ្មសម្រាប់ជីវភាពរស់នៅរបស់ពួកគេ។

## ការប្រែប្រួលអាកាសធាតុនិង ប្រជុំកោះរ៉ុង

នៅប្រទេសកម្ពុជាមានការវាយតម្លៃនៃការផ្លាស់ប្តូរអាកាសធាតុ គឺមាននៅលើតែដីគោកប៉ុណ្ណោះទេ ចំពោះសហគមន៍នៅតាមតំបន់ឆ្នេរ និងសមុទ្រវិញការចូលរួមយកចិត្តទុកដាក់នៅមានកំរិត។ គួរអោយសោកស្តាយណាស់ ដែលសហគមន៍ទាំងនេះក្លាយជាសហគមន៍ងាយរងគ្រោះបំផុត។ ដើម្បីអោយមានគុណភាពនៅក្នុងឆ្នាំ ២០១៩ នេះមូលនិធិកោះសង្ហា បានបញ្ចប់ការវាយតម្លៃហានិភ័យទៅលើភូមិចំនួនពីរនៅក្នុងប្រជុំកោះនេះ។

## ការរកឃើញនិងការយល់ដឹងរួមមាន:

- មានការប្រែប្រួលនៅរដូវវស្សាដោយមានភ្លៀងធ្លាក់យឺត និងមានរយៈពេលខ្លី។ ការប្រែប្រួលនេះបានធ្វើឲ្យមានផលប៉ះពាល់ដល់ការប្រើប្រាស់ទឹកក្នុងគ្រួសារ និងកសិកម្ម។ ផលប៉ះពាល់នេះធ្វើឲ្យការកើនឡើងនៃអវត្តមានសិស្សសាលា ដោយកុមារទាំងនោះត្រូវមានកាតព្វកិច្ចក្នុងការធ្វើដំណើរកាន់តែបន្ថែមទៀត ដើម្បីស្វែងរកទឹកសម្រាប់ក្រុមគ្រួសាររបស់ពួកគេ។
- ការខ្វះខាតទឹកអណ្តូង ដោយសារតែការផ្លាស់ប្តូរទឹកភ្លៀងបានធ្វើ
អោយមានភាពងាយស្រួលក្នុងការចម្លងមេរោគនិងសារពាង្គកាយងាយធ្លងជំងឺ
- ការកើនឡើងនៃខ្យល់ព្យុះ និងរន្ទះបាញ់ដែលបណ្តាលឱ្យមានការខូចខាតផ្ទះសម្បែងរបស់អ្នកភូមិ និងគ្រោះថ្នាក់ដល់ជីវិតមនុស្សនិងក្របី។
- នៅពេលដែលការប្រែប្រួលអាកាសធាតុមានការគំរាមកំហែងដល់សុខភាព និងសុខុមាលភាពនៃជីវិតនៅប្រជុំកោះរ៉ុងអ្នកភូមិមិនបាននៅស្ងៀមទេ គឺពួកគេលៃលករកយុទ្ធសាស្ត្រដើម្បីដោះស្រាយ។ ដូច្នេះហើយទើបមានការរួមបញ្ចូលការធ្វើការងារជាមួយមូលនិធិកោះសង្ហា និងអាជ្ញាធរដែនដីដើម្បីធ្វើការការពារព្រៃកោងកាង និងស្មៅសមុទ្រ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃព្រឹត្តិការណ៍ខ្យល់ព្យុះ។ នៅភូមិព្រែកស្វាយមានបច្ចេកទេសថ្មីក្នុងការថែរក្សាទឹករួមទាំងការផ្សព្វផ្សាយពីនៃការដាំរុក្ខជាតិនៅក្នុងផើងដោយការប្រើប្រាស់សំណល់រុក្ខជាតិសរីរាង្គ (កំប៉ុស)។

# Climate change-
# THE CRISIS OF OUR AGE

**Climate change**—it is hard to escape it, from global summits to internet blogs, not to mention the personal feeling that the 'weather isn't what it used to be.' The phenomenon is both the centre of debate and the shadow across the path of contemporary life. But what actually is it?

Climate change is derived from the culmination of human activities that cause the release of certain gases into the atmosphere. These 'greenhouse' gases—which include carbon dioxide, methane and nitrous oxide—cause heat to be trapped in the atmosphere, causing the earth's temperature to rise. Of the human actions contributing to this process, the burning of fossils fuels is one of the largest contributors.

The implications of rising temperatures for the globe are varied and severe. The melting of polar ice and the thawing of the Arctic tundra are already well known, but potentially more serious are consequences for planetary weather patterns.

The East Asian monsoon is an example. This system influences the lives of nearly half of the world's population, underpinning the agricultural and economic systems across five continents. Climate change is causing this weather pattern to alter, with rains arriving at different times and more infrequently, and often as damaging storms. Beyond humans, these adjustments have implications for plants and animals, with migratory and reproductive strategies placed at risk as species are forced to adjust to new climate imperatives.

## Climate change and the ocean

We are still seeking to grasp the consequences of climate change for the world's oceans. Melting icecaps and thermal expansion are already contributing to sealevel rise, but other impacts are equally concerning.

Coral bleaching is one such problem, which occurs when the protozoa that coral rely on to turn sunlight into food, are expelled as a consequence of thermal stress—the result being the bleached-white appearance synonymous with the condition. Thankfully for the planet's coral reefs, bleached corals do not necessarily die, but their growth is restricted until the protozoan is able to return. While this wait is occurring fish and other species, which depend

on the reefs for their wellbeing, face an uncertain future. The implication is a chain reaction across the ecosystem, which ultimately impacts upon the villagers who depend on the reefs for food.

## Climate change and the Koh Rong archipelago

In Cambodia assessments of climate change have focused on the mainland, with limited attention paid to coastal and marine communities. This is regrettable as it is communities in these places that are especially vulnerable to its impacts. To gauge this, in 2015 the Song Saa Foundation completed a vulnerability risk assessment of two villages in the archipelago. Its findings, insightful and sobering, included:

- A change in rainy season patterns, with the wet monsoon arriving later and ending sooner. This change has affected the availability of water for domestic and agricultural use. The effects of this have included increased incidences of school absenteeism, as children are obliged to travel further distances to find freshwater for their families.
- Well water, scarce because of the changing rainfall patterns, has become susceptible to contamination and disease-carrying organisms.
- A rising incidence of storm events and lightning strikes, which have resulted in damage to village homes and hazards to human life and water buffalo.

While climate change is a mounting threat to the health and well being of the communities of the Archipelago, villagers are not helpless and have responded with unique coping strategies. These have included working with the Song Saa Foundation, other organisations and government authorities to protect mangrove forests and sea-grass beds, which reduce the damaging effects of storm events. Villages in Prek Svay have also adopted new water conservation techniques, including the propagation of plants in pots and under organic mulch.

# ការផ្តួចផ្តើមធ្វើត្រីដូង

មានការបំផុសគំនិតដោយការតាំងពិព័រណ៍របស់សិល្បករនៅប្រទេសម៉ិកស៊ិកកូ ដើម្បីបង្កើនការយល់ដឹងអំពីចំនួននៃការបាត់អ្នកនៅក្នុងតំបន់គ្រប់ដណ្តប់ដោយការជួញដូរគ្រឿងញៀនមួយ ការផ្តួចផ្តើមត្រីដូងនេះជាឱកាសមួយ ដើម្បីនាំយកមកនូវពន្លឺជីវិតប្រចាំថ្ងៃរបស់ប្រជាជននៃកោះរ៉ុងក្នុងពេលដែលមានការប្រែប្រួលអាកាសធាតុ។

កុមារដែលបានចូលរួមបានបង្កើតត្រីដ៏ស្រស់ស្អាតរបស់ខ្លួននេះ គឺគ្មានអ្វីដែលត្រូវយកមកប្រើច្រើននោះទេ ក្រៅពីផ្លែដូង ស្លឹកដូង និងការគូរគំនូរនៅពីលើវា។ ពួកគេបានបន្ថែមប្រយោគខ្លីៗរបស់ពួកគេផ្ទាល់ទៅលើការប្រែប្រួលអាកាសធាតុគឺសម្រាប់ពួកគេមានចំណាប់អារម្មណ៍សំខាន់ និងដោយផ្ទាល់នូវអ្វីដែលកំពុងកើតឡើងនៅទូទាំងពិភពលោក ប៉ុន្តែត្រូវបានប៉ះពាល់ដល់ប្រជាជននៅកម្រិតសហគមន៍ និងគ្រួសារ។

# The Coconut Fish Initiative

Inspired by the exhibition of a Mexican artist the Coconut Fish Initiative is an opportunity to shed light on the daily life of the people of the Koh Rong Archipelago in an age of climate change.

The children who participated created their colourful fish with nothing but coconuts, leaves and paint; to which they added—on the fish itself—a sentence of what climate change means to them. Overall, a simple but elegant way to show how global change is affecting life at the most elementary of levels.





## ម៉ាន សំរេច

ការប្រែប្រួលអាកាសធាតុគឺជាមូលហេតុ មួយដែលបានបង្ហាញប្រាប់ថានៅក្នុងឆ្នាំ នេះយើងមិនមានទឹកគ្រប់គ្រាន់សម្រាប់ ប្រើប្រាស់ប្រចាំថ្ងៃរបស់យើងឡើយ។

## Marn Samrach

Climate change is the reason why, at some point in the year, we do not have enough water for our everyday activities





## ឆាង ឆាយមុន្នី

ការប្រែប្រួលអាកាសធាតុគឺជាមូលហេតុដែលធ្វើអោយ, ក្នុងអំឡុងរដូវប្រាំងក្ដៅខ្លាំងដែលវាធ្វើអោយមានលំបាកសូម្បីតែអង្គុយនៅក្នុងបន្ទប់រៀន។

## Chharng Chay Mony

Climate change is the reason why, during the dry season, it gets so hot that it becomes difficult to stay in the classroom.





## ណងសុភ័ណ្ឌ

ដោយសារតែការប្រែប្រួលអាកាសធាតុ ទើបធ្វើឲ្យរដូវវស្សាមានខ្យល់ព្យុះច្រើនជាងអ្វីដែលធ្លាប់ជួបពីមុនមក។

## Norng Sophean

Because of climate change there are now many more storms in the rainy season than there used to be.





## សឹង សង

រដូវក្តៅមានរយៈពេលវែងជាមុន ប៉ុន្តែរដូវភ្លៀងនាំមកនូវខ្យល់ព្យុះខ្លាំង

## Seung Sorng

The dry season is much longer than before, but the rainy season brings bigger storms





## ឆន ប៊ុនឆៃ

*ការធ្វើដំណើរនិងការនេសាទមានការ
លំបាកជាងមុន ដោយសារតែមានខ្យល់
ព្យុះកាន់តែច្រើន និងរលកខ្លាំង។*

## Chhorn Bun Chhai

Travelling and fishing is more difficult because there are more storms and the waves are higher.





## ឈាង សុននឹង

រដូវប្រាំងគឺមានរយៈពេលយូរជាងមុន
ដូច្នេះមិនមានការទឹកប្រើប្រាស់គ្រប់គ្រាន់
និងធ្វើរុក្ខជាតិងាប់។

## Leng Son Neung

The dry season is longer than before, so there is not enough water and plants die.





## ហ៊ុន ស្រីប៉ា

មុនពេល និងកំឡុងពេលរដូវប្រាំងយើងបានយកចិត្តទុកដាក់ក្នុងការសន្សំសំចៃទឹកប៉ុន្តែគឺមានសម្រាប់តែរយៈពេលបីខែទេ ដោយឡែកឥឡូវនេះយើងត្រូវមានការប្រុងប្រយ័ត្នសម្រាប់រយៈះពេលយូរជាងនេះ។

## Hun Srey Pa

Before, during the dry season, we had to think to save water, but only for three months, now we need to be careful for longer.



## ផន ឈៀងម៉ៃ

រដូវវស្សា យើងមានការភ័យខ្លាចនឹងរន្ទះ
បាញ់ខ្លាំងណាស់នៅខណៈពេលដែលមាន
ខ្យល់ព្យុះម្តងៗ។

## Phon Cheangmai

In the rainy season we have more scary lightning during storms.







## តែម សុថាត់

ការប្រែប្រួលអាកាសធាតុនាំមកនូវខ្យល់ព្យុះញឹកញាប់និងកាន់តែខ្លាំងជាងមុន។

## Tem Sothart

Climate change is bringing more storms than ever and they have never been so strong





## ស៊ិន សុភា

*ការប្រែប្រួលអាកាសធាតុធ្វើអោយក្តៅខ្លាំង ហេតុនេះហើយទើបយើងមិនមានទឹកគ្រប់គ្រាន់។*

## Sorn Sophea

With climate change it gets very hot and because of this we don’t have enough water.

"ការផ្លាស់ប្តូរអាកាសធាតុមិនអាចត្រូវបានបដិសេធ ឬ មិនអើពើបាននោះទេ។ ជាការពិតណាស់ វានឹងកើតឡើងនៅពេលឥឡូវនេះ ហើយវាមិនត្រឹមតែផ្តល់ផលប៉ះពាល់ច្រើនចំពោះការអភិវឌ្ឍមនុស្សនោះទេ ថែមទាំងប៉ះពាល់ដល់បញ្ហាបរិស្ថានផងដែរ"។

Cambodia Human Development Report, 2011.

“Climate change can no longer be denied or simply ignored. It is real, it is happening now, and it is as much a human development issue as it is an environmental issue.”

Cambodia Human Development Report, 2011.

# ការបោះជំហានទៅមុខ

## ក្នុងឆ្នាំ ២០១៣ មូលនិធិកោះសង្សាបានបង្កើតឡើងដោយខ្លួនឯងដើម្បីលើកកំពស់ សុខភាព និងសុខុមាលភាពរបស់ប្រជាជននិងបរិស្ថាននៃប្រជុំកោះរ៉ុង។ ការងារនេះបានរួមមាន:

- ការគាំទ្រជីវភាពរស់នៅរបស់ប្រជាជននៅទីនោះរួមទាំងការផ្តល់វគ្គបណ្តុះបណ្តាល និងស្វែងរកទីផ្សារសម្រាប់វិស័យកសិកម្មសរីរាង្គ និងការដាំផ្សិត។
- ការសម្របសម្រួល និង ធ្វើឲ្យវិស័យអប់រំមានភាពប្រសើរឡើង រួមទាំងបង្កើតការអប់រំបណ្តុះបណ្តាល អំពីបរិស្ថាននៅក្នុងភូមិ និងការផ្តល់អាហាររូបករណ៍ទៅកាន់ក្មេងៗ នៅក្នុងភូមិ។
- ការផ្តល់បេសកកម្មពេទ្យប្រចាំឆ្នាំដែលធ្វើឡើងដោយអ្នកជំនាញផ្នែកសុខភាពអន្តរជាតិ ដើម្បីធ្វើការពិនិត្យសុខភាពប្រជាពលរដ្ឋនៅជុំវិញប្រជុំកោះនេះ។ ហើយវាត្រូវបានគាំទ្រឲ្យមានការផ្តល់សេវាសុខភាពប្រចាំខែដល់អ្នកភូមិដោយគ្រូពេទ្យពីកោះសង្សាផងដែរ។

មូលនិធិកោះសង្សាគឺជាអង្គការប្រចាំនៅកម្ពុជាមួយ ដែលធ្វើការទៅលើការលើកកម្ពស់ការអភិរក្សតាមតំបន់ឆ្នេរ និងសមុទ្រនៅប្រជុំកោះរ៉ុង មូលនិធិនេះធ្វើការទៅលើសកម្មភាពអភិរក្ស និងការសិក្សាស្រាវជ្រាវ ហើយមូលនិធិនេះបានធ្វើការសហការជាមួយអង្គការសត្វព្រៃ និងរុក្ខជាតិ អន្តរជាតិដែលជាអង្គការក្រៅរដ្ឋាភិបាល (FFI) រដ្ឋបាលជលផល និងអាជ្ញាធរមូលដ្ឋាន( ក្រុមប្រឹក្សាឃុំ) និងទទួលបានការឧបត្ថម្ភពីមូលនិធិព្រះអង្គម្ចាស់ Albert ដើម្បីអភិរក្សនៅតំបន់ឆ្នេរ និង ប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងប្រភេទសត្វដែលបានហៅសមុទ្រថាជាផ្ទះ។

ការងារនេះបានរួមចំណែកដល់ការការពារទីជម្រកដូចជាផ្កាថ្ម ព្រៃកោងកាង និងស្មៅសមុទ្រ ដែលមានតម្លៃបំផុតនៅតំបន់ទន្លេមេគង្គក្រោម។ នៅឆ្នាំ ២០១៦ លទ្ធិផលដែលបានមកពីការកិច្ចខិតខំប្រឹងប្រែង រួមចំណែកនេះ ប្រជុំកោះរ៉ុងត្រូវបានប្រកាសជាតំបន់គ្រប់គ្រងជលផលសមុទ្រទីមួយប្រចាំប្រទេសកម្ពុជា។

# បេសកកម្មទូកនៃក្ដីសង្ឃឹម

នៅក្នុងការសម្ពោធការអភិវឌ្ឍមូលនិធិទទួលបានជំនួយសប្បុរសធម៌ទូកមួយបន្ថែម ដើម្បីគាំទ្រដល់ការងាររបស់ខ្លួន។ គំនិតផ្ដួចផ្ដើម - ទូកនៃក្ដីសង្ឃឹមនេះ ជាមធ្យោបាយធ្វើដំណើរសម្រាប់ឲ្យមូលនិធិ យកទៅភ្ជាប់ជាមួយមូលនិធិពីសកម្មភាពរបស់ខ្លួន និងបានចំណាយពេលវេលាកាន់តែច្រើនទៀតជាមួយនឹងសហគន៍នៅទូទាំងប្រជុំកោះរ៉ុង។ ចំណែកមួយរបស់ទូកនៃក្ដីសង្ឃឹមបានចូលរួមក្នុងការប្រមូលទិន្នន័យវិទ្យាសាស្ត្រ ដែលអាចប្រើប្រាស់សម្រាប់ការត្រួតពិនិត្យផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើបរិស្ថាន និងសហគមន៍នៅក្នុងតំបន់នោះព្រមទាំងការផ្ដល់ការគាំទ្រដល់សហគមន៍ ដែលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ

នេះផងដែរ។

# Making Waves:
# THE SONG SAA FOUNDATION

Since 2013 the Song Saa Foundation has dedicated itself to improving the health and well being of the people and environments of the Koh Rong archipelago.

The Song Saa Foundation is the leading Cambodia-based organisation promoting coastal and marine conservation in the archipelago.

Undertaking research and conservation activities, the Foundation has worked with non-government agencies (Fauna & Flora International) and is supported by the Asian Development Bank and Plan International.The Foundation works hand-in-hand with government authorities (the Ministry of Environment, Fisheries Administration and the commune council) to conserve the region's coastal and marine ecosystems, and the creatures that call them home.

This work has contributed to the protection of some of the most valuable reef, mangrove and seagrass habitats in the lower Mekong region. In 2016 these efforts culminated with the creation of Cambodia's first marine protected are: the Koh Rong Archipelago Marine Fisheries Management Area.

In addition, the Foundation supports livelihood opportunities, encompassing training and market access for organic agriculture and mushroom growing.

Meanwhile, an annual medical mission brings internationally trained health professionals to complete clinics across the archipelago, backed by monthly outreach from Song Saa Private Island's medical personnel.




Plan International's Civil Society Support Mechanism is funded by the Climate Investment Fund under the Pilot Program for Climate Resilience. It is administered by the Asian Development Bank through Plan International Cambodia. This work is conducted under the auspices of the Climate Change Department of the National Council for Sustainable Development, within the Ministry of Environment of Cambodia.

The project funds 19 Cambodian CSOs in 17 provinces to implement Community-Based Climate Change Adaptation (CCA) and Disaster Risk Reduction (DRR) initiatives across a variety of sectors and targets the most vulnerable. Grants range from US$40,000 to US$100,000 with a duration of 18 months.

Room 411, 4th fl., Block A, Phnom Penh Centre
Sangkat Tonle Basac, Khan Chamkarmorn
Phnom Penh, Kingdom of Cambodia.
Tel : +855 (23) 217 214
Website : www.plan-international.org/cambodia




CLIMATE INVESTMENT FUNDS

ADB

Preah Sihanouk Province

SONG SAA FOUNDATION

#10, St. 618, Toul Kork, Phnom Penh
Kingdom of Cambodia
Tel: +855 (0) 77 777 498
E-mail: wayne@songsaa.com

Climate change poses a severe challenge to environment and human well being in the Koh Rong archipelago of southern Cambodia. With US$49,984 funding support from the Asian Development Bank and Plan International and some of its own contribution, the Song Saa Foundation is implementing an action plan to manage some of the key impacts of climate change on communities of the archipelago region.

Between July 2016 and December 2017, it has constructed rainwater harvesting facilities in local villages and distributed water filters, both projects addressing the consequences of climate change on water supply and quality. The Foundation is also working to promote mangrove protection and planting, as well as raising public awareness of climate change through knowledge building activities.



SONG SAA
FOUNDATION

Plan

ISBN-13-978-9924-9167-0-3
9 789924 916703